# ឧបសម្ព័ន្ធ
# សេចក្តីថ្លែងការណ៍ព័ត៌មាន ស្តីពី
# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៦

**អនុសាសន៍សំខាន់ៗរបស់អង្គការតម្លាភាពកម្ពុជា មានដូចខាងក្រោម៖**

១. ត្រូវធានានូវឯករាជ្យភាពរបស់ស្ថាប័នតុលាការ

២. ត្រូវធានានូវឯករាជ្យភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ

៣. ត្រូវបង្កើននូវបរិយាកាស និងលក្ខខណ្ឌសមស្រប សម្រាប់ធុរៈកិច្ច និងការវិនិយោគស្អាតស្អំ

៤. ត្រូវអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឲ្យទាន់ពេលវេលា ដើម្បីធានាឲ្យមានការបើកចំហព័ត៌មានជាអតិបរមា និងការអនុវត្តចំពោះជនគ្រប់រូបដោយគ្មានការរើសអើង

៥. ត្រូវអនុម័តច្បាប់ស្តីពីការការពារបុគ្គលរាយការណ៍ ដែលអនុលោមតាមបទដ្ឋានអន្តរជាតិ

៦. ត្រូវធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ប្រឆាំងអំពើពុករលួយបច្ចុប្បន្ន រួមទាំងការសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការប្រកាសទ្រព្យសម្បត្តិ ហើយដាក់បញ្ចូលទាំងការប្រកាសទ្រព្យសម្បត្តិរបស់ប្តី ប្រពន្ធ និងសមាជិកក្រុមគ្រួសារផ្ទាល់ផងដែរ

៧. ត្រូវលុបបំបាត់នូវការអនុវត្តបែបបក្សពួកនិយម និងទំនាស់ផលប្រយោជន៍ក្នុងស្ថាប័នសាធារណៈ

៨. ត្រូវលើកកម្ពស់វប្បធម៌បែបសុចរិតភាព តម្លាភាព និងគណនេយ្យភាពលើគ្រប់ស្រទាប់នៃសង្គម

**អនុសាសន៍សំខាន់ដែលមាននៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិរបស់អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៤ មានដូចជា៖**

**ធ្វើកំណែទម្រង់ស្ថាប័នតុលាការ ជាពិសេស៖**

- ធានាថាសាលសវនាការទាំងអស់ បើកចំហសម្រាប់ជនគ្រប់រូប
- បោះពុម្ពផ្សាយសេចក្តីសម្រេចរបស់ចៅក្រម និងសំអាងហេតុ អំពីសេចក្តីសម្រេចទាំងនោះ
- ធានាថាចៅក្រមត្រូវបានជ្រើសរើសដោយសត្យានុម័ត តាមរយៈស្ថាប័នចាត់តាំងណាមួយដែលមានឯករាជ្យភាព
- តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ពិនិត្យឡើងវិញ និងធ្វើកំណែទម្រង់លើច្បាប់ស្តីពីស្ថាប័នតុលាការទាំងបី ដើម្បីធានាឲ្យបាននូវឯករាជ្យភាពពិតប្រាកដរបស់ស្ថាប័ន តុលាការ។

**ធ្វើវិសោធនកម្មច្បាប់ប្រឆាំងអំពើពុករលួយ ជាពិសេស៖**

- មាត្រា៤១ ដែលអាចធ្វើឱ្យអ្នកដាក់ពាក្យបណ្តឹងអំពីបទល្មើសពុករលួយ ជាប់ពន្ធនាគារទៅវិញ គួរលុបចោល
- មាត្រា២០ គួរតែធ្វើវិសោធនកម្មដើម្បីដាក់បន្ថែមនូវបញ្ញត្តិមួយដែលចែងថា ការប្រកាស ទ្រព្យសម្បត្តិត្រូវតែធ្វើឡើងជាសាធារណៈហើយរួមបញ្ចូលទាំងការប្រកាសទ្រព្យសម្បត្តិ របស់ប្តី ប្រពន្ធ និងសមាជិកក្រុមគ្រួសារផ្ទាល់។

**អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ជាពិសេស៖**

- ធានាឲ្យមានការបើកចំហព័ត៌មានជាអតិបរមា
- ដាក់កាតព្វកិច្ចឲ្យស្ថាប័នសាធារណៈ បើកចំហព័ត៌មាន
- ធានាថាព័ត៌មានត្រូវផ្តល់ជូនតាមសំណើដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប
- រួមបញ្ចូលនូវការការពារចំពោះបុគ្គលរាយការណ៍។

**ធ្វើកំណែទម្រង់វិស័យសាធារណៈ ជាពិសេស៖**

- ធ្វើការចេញផ្សាយព័ត៌មានលម្អិតអំពីការចំណាយ កិច្ចសន្យាលទ្ធកម្ម និងថ្លៃសេវា
- ធានានូវប្រាក់បៀវត្សរ៍គ្រប់គ្រាន់សម្រាប់មន្ត្រីរាជការ។